**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

# កិច្ចព្រមព្រៀង
# រវាង
# រោងចក្រ ខេវីធី អ៊ីអិមប៊ី បេស (ខេមបូឌា) ឯ.ក
# ជាមួយប្រតិភូបុគ្គលិក តំណាងកម្មករនិយោជិតទាំងអស់

នៅថ្ងៃទី៥ ខែមេសា ឆ្នាំ២០២៥ វេលាម៉ោង ៨:០០ព្រឹក នៅសហគ្រាស **ខេវីធី អ៊ីអិមប៊ី បេស (ខេមបូឌា) ឯ.ក** មានកិច្ចប្រជុំមួយរវាងប្រធានរដ្ឋបាល និងប្រតិភូបុគ្គលិក ជំនួសឲ្យកម្មករនិយោជិតសរុបចំនួន ១៦នាក់។ ក្នុងអង្គប្រជុំនេះ ប្រធានរដ្ឋបាលបានជូនដំណឹងដល់ប្រតិភូបុគ្គលិក ស្តីពីស្ថានភាពបច្ចុប្បន្ននៃរោងចក្រដែលមិនមានការបញ្ជាទិញពីអតិថិជននាំឱ្យមានផលប៉ះពាល់រោងចក្រ។ ហេតុដូចនេះរោងចក្រសម្រេចព្យួរកិច្ចសន្យាការងារកម្មករនិយោជិតចំនួន **១៥នាក់ (ស្រី១០នាក់)** ក្នុងចំណោមកម្មករនិយោជិតសរុបចំនួន ១៦នាក់ (ស្រី១០នាក់) រយៈពេល**៥២ថ្ងៃ** ដោយគិតចាប់ពី**ថ្ងៃទី១០ ខែមេសា ឆ្នាំ២០២៥** រហូតដល់**ថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០២៥**។ ក្នុងកំឡុងពេលព្យួរកិច្ចសន្យាការងារនេះកម្មករនិយោជិតបានឯកភាពទទួលយកការផ្តល់ជូនរបស់រោងចក្រនូវប្រាក់ឧបត្ថម្ភចំនួន ៦០ដុល្លា (60$) ក្នុងនោះ៖

- ចំនួន៣០ដុល្លា ពីថ្ងៃទី១០ ដល់ថ្ងៃទី៣០ ខែមេសា ឆ្នាំ២០២៥
- ចំនួន៣០ដុល្លា ពីថ្ងៃទី០១ ដល់ថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០២៥

ប្រាក់ឧបត្ថម្ភក្នុងកំឡុងពេលព្យួរកិច្ចសន្យាការងារនេះនឹងបើកជូនកម្មករនិយោជិតរៀងរាល់ថ្ងៃទី១០នៃខែបន្ទាប់។

អង្គប្រជុំបានបញ្ចប់នៅវេលាម៉ោង ៨:៥០នាទីព្រឹកនា ថ្ងៃខែឆ្នាំដដែលប្រកបដោយបរិយាកាសរីករាយ និងស្និទ្ធស្នាលក្រោមស្មារតីទទួលខុសត្រូវខ្ពស់ និងយោគយល់សហការគ្នាយ៉ាងរលូន។

រាជធានីភ្នំពេញ, ថ្ងៃទី៥ ខែមេសា ឆ្នាំ២០២៥

ហត្ថលេខា និងត្រាក្រុមហ៊ុន

**នាយកក្រុមហ៊ុន**

ស្នាមមេដៃប្រតិភូបុគ្គលិក